ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ
និង អតីតយុទ្ធជន
លេខ ០៥ សករ/94

ភ្នំពេញ ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ១៩៩៤

# ប្រកាសរួម
## ក្រសួងសង្គមកិច្ចការងារនិងអតីតយុទ្ធជន និង ក្រសួងសុខាភិបាល

## ស្តីពីការចាត់តាំង បណ្តាញពេទ្យការងារ

**រដ្ឋលេខាធិការក្រសួងសង្គមកិច្ច ការងារ និង អតីតយុទ្ធជន**
**រដ្ឋមន្ត្រី ក្រសួង សុខាភិបាល**

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ការងារដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ៩៩ក្រ ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ១៩៩២

## សម្រេច

ប្រការ១: គ្រប់រោងចក្រសហគ្រាស គ្រឹះស្ថានឧស្សាហកម្ម រ៉ែ ពាណិជ្ជកម្ម សិប្បកម្ម កសិកម្ម សេវាកម្ម សហគ្រាស ដឹក ជញ្ជូនតាមផ្លូវថ្នល់ឬតាមទន្លេ ទោះជាប្រយោជន៍សាធារណៈ ពាក់កណ្តាល សាធារណៈ ឬឯកជន ក្រៅសាសនា ឬ ក្នុង សាសនាក៏ដោយ ទោះបីជាមានលក្ខណៈជាការបង្រៀន វិជ្ជាជីវៈ ជាការកុសលក៏ដោយ ត្រូវរៀបចំចាត់តាំង បណ្តាញពេទ្យការងារ ដើម្បីធានា សន្តិសុខការងារ អនាម័យការងារ និងសុខភាពរបស់និយោជិតនិងកម្មកររបស់ខ្លួន ។ ក៏ប៉ុន្តែមិនត្រូវអនុវត្តបទបញ្ញត្តិនេះ ចំពោះរោងជាងទាំងឡាយណាដែលមានប្រើតែ និយោជិតជា សមាជិកនៃគ្រួសារ ដែលឋិតនៅ ក្រោមការគ្រប់គ្រង របស់ ឪពុកម្តាយ ឬអ្នកអាណាព្យាបាលប៉ុណ្ណោះលើកលែងតែការងារប្រព្រឹត្តទៅដោយ ឡចំហាយ ឬគ្រឿងយន្ត ឬអគ្គិសនី ឬក៏ឧស្សាហកម្ម ទោះជាគ្រឹះស្ថានដែលអាចមានគ្រោះថ្នាក់ ឬ ខូចសុខភាព ។

សហគ្រាសនិងគ្រឹះស្ថានដែលចង្អុលក្នុងមាត្រា១នៃច្បាប់ការងារ ត្រូវអោយមានព្យាបាលជម្ងឺដោយឥតគិតថ្លៃ សំរាប់អ្នកស៊ីឈ្នួលទៀងទាត់របស់ខ្លួន និងគ្រួសារអ្នកស៊ីឈ្នួលទាំងនោះ ។

ប្រការ២: គ្រប់រោងចក្រសហគ្រាស និងក្រុមហ៊ុនដែលបានចែងក្នុងប្រការ១ ហើយដែលមានប្រើអ្នកស៊ីឈ្នួលយ៉ាងតិច ៥០នាក់ ត្រូវរៀបចំគិលានដ្ឋានអចិន្ត្រៃយ៍មួយអោយបានសមរម្យតាមល័ក្ខខ័ណ្ឌខាងក្រោម ៖

- មានទំហំសមស្របទៅតាមចំនួនបុគ្គលិក កម្មករ ប៉ុន្តែយ៉ាងតូចបំផុតអោយមានទំហំផ្ទៃ ១៦ ម៉ែត្រក្រឡា ។
- មានភាពងាយស្រួលដល់អ្នកជម្ងឺចេញចូល.

- អាគារពុំមានខ្យល់អាកាសចេញចូលគ្រប់គ្រាន់.

- មានធាតុពិសពុល ធូលី ផ្សែង កាកសំណល់ផ្សេងៗ

កាលណាសហគ្រាស មានសាខា ឬការដ្ឋានមួយ ឬច្រើនដែលមានប្រើអ្នកស៊ីឈ្នួលយ៉ាងតិច ៥០ នាក់ ហើយស្ថិតនៅចម្ងាយលើសពី ៨ គីឡូម៉ែត្រ (៥ ត.ម)ពីការដ្ឋានធំនិយោជកត្រូវតែផ្តល់ចំពោះសាខា ឬការដ្ឋានទាំងនោះអោយមានដូច ជាការដ្ឋានធំដែរ នូវមន្ទីរពេទ្យសង្គ្រោះនិងព្យាបាលអ្នកស៊ីឈ្នួលខ្លួន អោយបានសព្វគ្រប់ដូចជាបុគ្គលិកពេទ្យ សំណង់ សំភារៈវត្ថុរុំរបួសនិងថ្នាំព្យាបាល ។

ប្រការ៣: គ្រប់រោងចក្រ សហគ្រាសក្រុមហ៊ុនផ្សេងៗដូចមានចែងក្នុងប្រការ ១ ខាងលើត្រូវមានបុគ្គលិកធ្វើការក្នុងគិលានដ្ឋានរបស់ខ្លួន ជាប្រចាំដូចតទៅ ៖

- គ្រូពេទ្យមធ្យម០១នាក់និងគិលានុបដ្ឋាក ឬគិលានុបដ្ឋាយិកា០១នាក់ សំរាប់បុគ្គលិកកម្មករចាប់ពី៥០នាក់ ទៅ២០០នាក់ ។

- គ្រូពេទ្យមធ្យម ០១នាក់ និងគិលានុបដ្ឋាកឬគិលានុបដ្ឋាយិកា០២នាក់ សំរាប់បុគ្គលិក កម្មករ ចាប់ពី ៤០០នាក់ ឡើងទៅ ។

- ក្នុងករណីពិសេស ត្រូវមានវេជ្ជបណ្ឌិត ០១នាក់ និងគិលានុបដ្ឋាក ឬគិលានុបដ្ឋាយិកា ០១នាក់ ឬ០២នាក់ ធ្វើការជាប្រចាំផងដែរដោយពុំគិតចំនួនបុគ្គលិក កម្មករឡើយចំពោះរោងចក្រ សហគ្រាស ឬក្រុមហ៊ុនណាដែលប្រកបដោយហានិភ័យ ខ្ពស់ ឬក្នុងករណីដែលក្រសួងសង្គមកិច្ច ការងារនិងអតីតយុទ្ធជនយល់ឃើញថា ចាំបាច់ត្រូវមាន វេជ្ជបណ្ឌិត ធ្វើការជាប្រចាំ ។

- ចំពោះសហគ្រាស ដែលមានវេនម៉ោងធ្វើការទាំងថ្ងៃទាំងយប់ ត្រូវមានគិលានុបដ្ឋាក ឬ គិលានុបដ្ឋាយិកាយ៉ាងតិច ០១នាក់យាមប្រចាំការជាអចិន្ត្រៃយ៍ ។

ប្រការ៤: ចំពោះរោងចក្រ សហគ្រាស ឬក្រុមហ៊ុនផ្សេងៗណាដែលមានអ្នកស៊ីឈ្នួលតិចជាង ២០នាក់ ត្រូវមានអ្នកជំនួយសង្គ្រោះ០១នាក់ និងប្រអប់សង្គ្រោះមួយ ។

- ចំពោះរោងចក្រ សហគ្រាស ឬក្រុមហ៊ុនផ្សេងៗណាដែលមានអ្នកស៊ីឈ្នួល ចាប់ពី២០នាក់ ទៅ៥០នាក់ ត្រូវមានបន្ទប់រុំរបួសមួយ និងគិលានុបដ្ឋាក ឬគិលានុបដ្ឋាយិកា០១នាក់ ។

- ចំពោះសហគ្រាសដែលមានអ្នកស៊ីឈ្នួល មិនគ្រប់ចំនួន និងត្រូវបង្កើតគិលានដ្ឋានអចិន្ត្រៃយ៍មួយ សហគ្រាសទាំងនោះអាចរួមសហការ ជាមួយសហគ្រាសផ្សេងទៀត ដែលស្ថិតនៅជិតគ្នា ដើម្បីបង្កើតជាគិលានដ្ឋានអចិន្ត្រៃយ៍ មួយហៅថាគិលានដ្ឋានអន្តរសហគ្រាស ។

<u>ប្រការ៥:</u>

ក -<u>ប្រអប់សង្គ្រោះត្រូវមានជាចាំបាច់</u> :

-សំភារៈរុំរបួស

-សំភារៈសម្រាប់ឃាត់ឈាម និងថ្នាំផ្សេងៗដូចជាថ្នាំបំបាត់ការឈឺចាប់

-ថ្នាំបញ្ចុះកំដៅ ថ្នាំទប់ទល់និងការរាករូស ក្អួត ថ្នាំប្រឆាំងនឹងការរលាកភ្លើង

-ប្រេងខ្យល់ ប្រេងកូឡា ជាដើម ។

ខ -<u>បន្ទប់រុំរបួស ត្រូវមានជាចាំបាច់នូវ</u> :

- ប្រអប់សង្គ្រោះបឋម
- ក្រណាត់រុំរបួស
- ពូក កៅអី
- ភ្លើងបំភ្លឺ

៣ គិលានដ្ឋាន :

ក្នុងគិលានដ្ឋាននីមួយៗ ត្រូវមានគ្រែ២យ៉ាងតិច គ្រែមួយសំរាប់ព្យាបាលជំងឺ គ្រែមួយទៀតសំរាប់សង្គ្រោះបន្ទាន់ ។

កាលណាចំនួនអ្នកស៊ីឈ្នួលមានច្រើនជាង ៤០០នាក់ ក្រៅពីគ្រឿងបរិក្ខារ និងថ្នាំព្យាបាល គិលានដ្ឋានត្រូវមាន កន្លែងសំរាប់សំរាកអ្នករបួស និងអ្នកជំងឺសំរាក មុននឹងបញ្ជូនទៅមន្ទីរពេទ្យធំ ឬសំរាប់ដាក់អ្នកជំងឺឆ្លងរោគនៅឆ្ងាយពីគេ កាលណាត្រូវការ ។ ពីកន្លែងទាំងនោះត្រូវមានលទ្ធភាពដាក់អ្នកជំងឺសំរាកអោយបាន ០២ភាគរយ នៃអ្នកស៊ីឈ្នួលដែលប្រើក្នុងការដ្ឋាន។

ក្រៅពីវិធានការដែលចែងខាងលើ និយោជកត្រូវតែចាត់ចែង ដោយចេញសោហ៊ុយខ្លួនឯងផ្ទាល់ :

១ -ក្រុមពិនិត្យ បង្ការរោគនៅក្នុងការដ្ឋានខ្លួន

២ -ការចាក់ថ្នាំការពារជំងឺឆ្លងទាំងឡាយដោយប្រើស៊ីរ៉ាំង និងម្ជុលចាក់មួយចោល ។

ប្រការ៦: សោហ៊ុយចំណាយក្នុងការរៀបចំគិលានដ្ឋាននិងការប្រព្រឹត្តទៅ នៃក្រុមពេទ្យការងារព្រម ទាំងការព្យាបាល ថែទាំ និងអាហារនៃអ្នករបួសនិងអ្នកជំងឺសំរាកក្នុង គិលានដ្ឋានសហគ្រាស ត្រូវនៅក្នុងបន្ទុកនិយោជក ។

ប្រការ៧: ការប្រព្រឹត្តល្មើស ឬមិនអនុវត្តតាមបទបញ្ញត្តិទាំងឡាយនៃប្រកាសនេះ ត្រូវពិន័យជាប្រាក់ ឬទទួលទោសដូចមានចែង ក្នុងមាត្រា ២៨៦ ២៨៧ ២៨៩ នៃច្បាប់ការងារ ។

ប្រការ៨: ប្រកាសនេះ មានប្រសិទ្ធិភាព អនុវត្តចាប់ពីពេលចុះហត្ថលេខាតទៅ ។

ចម្លងជូន :
ទីស្តីការគណៈរដ្ឋមន្ត្រី
ក្រសួងយុត្តិធម៌
ក្រសួងមហាផ្ទៃ
"ដើម្បីជូនជ្រាប"
ក្រសួងព័ត៌មាន
"ដើម្បីជួយផ្សព្វផ្សាយអោយបានទូលំទូលាយ"
គ្រប់អធិការដ្ឋានសង្គមកិច្ច ការងារ
និងអតីតយុទ្ធជន ខេត្ត ក្រុង
"ដើម្បីអនុវត្ត"
រាជកិច្ច
ឯកសារ កាលប្បវត្តិ

រដ្ឋមន្ត្រីក្រសួងសុខាភិបាល

[illegible]

រដ្ឋលេខាធិការក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន

ស៊ុយ. សែម

010

24

[illegible]